ខេត្តខ្លះនៃសហភាពសូវៀតផង ហើយបណ្ដាលឲ្យកើតមានសង្គ្រាមយ៉ាងយូរ ពីឆ្នាំ ១៩៣៧ ទៅទល់នឹងឆ្នាំ ១៩៤៥ រវាងចិននិងជប៉ុន ។

ឯប្រទេសអាល្លឺម៉ាញវិញក៏បានអនុវត្តនយោបាយពង្រីកទឹកដីតាំងពីឆ្នាំ១៩៣៨មកដល់ឆ្នាំ ១៩៤៥ ដោយបានវាយដណ្ដើមយកប្រទេស អូទ្រីស, ប៉ូឡូញ នឹងចាកគត់នៃមហាប្រទេសរុស្ស៊ី ។ល។ ជាពិសេសទៅទៀត គេបានកត់សំគាល់ថា មានកំណើនចំនួនបណ្ដាជនខ្លាំងក្នុង ទ្វីបអឺរ៉ុបពីឆ្នាំ ១៨១៥ មកដល់ឆ្នាំ ១៩១៤ ហើយស្រាប់តែនៅដើមសតវត្សរ៍ទី ២០ នេះតែម្ដង ទ្វីបអឺរ៉ុបបានឆ្លងកាត់នូវសម័យមួយដ៏រំជើបរំជួល ហើយប្រទះនូវមហាសង្គ្រាមដល់ទៅពីរលើក គ្រាន់តែក្នុងរយៈពេលកណ្ដាលនៃ សតវត្សរ៍ ទី២០ តែប៉ុណ្ណោះ ។

ជាចុងបំផុតគេសង្កេតឃើញម្យ៉ាងទៀតថា ក្នុងសម័យបច្ចុប្បន្ននេះ គ្រប់ប្រទេសខ្សត់ខ្សោយទាំងឡាយនៃពិភពលោក( les pays sous développés) ដែលទើបនឹងបានស្គាល់



នូវកំណើនចំនួនបណ្ដាជន ដ៏លឿនហាក់បីដូចជាសន្ទុះព្រួញកំពុងតែជួបប្រទះនូវ ចលនាបដិវត្តន៍ មួយដែលកំពុងតែរាលដាលផ្សព្វផ្សាយគ្រប់ទិសទី ដោយមានអង្គការកុម្មុយនិស្តនិយមអន្តរជាតិជួយជ្រោមជ្រែងផង ។ ហើយចលាចលកើតតែ ពីចំណុចនេះ ក្រៅពីនេះទៅទៀតបំផ្លិចក្នុងគោលបំណងនឹងរំលំរបប នយោបាយសេដ្ឋកិច្ច សង្គមចាស់តាមការឲ្យមានរបបថ្មី ប្រកបដោយលក្ខណៈបដិវត្តន៍ ដែលគេយល់ថានឹងការដោះស្រាយបញ្ហាសង្គមមនុស្សបានដោយប្រសិទ្ធភាព ពិសេស បញ្ហាដែលទាក់ទងទៅនឹងកំណើនដ៏លឿនហួសប្រមាណ នៃបណ្ដាជននេះឯង ។ ក៏ក្នុងក្របខណ្ឌនៃទ្រឹស្ដីនេះឯងទៀត ដែលមានអ្នកប្រាជ្ញខ្លះមានលោក ហ្គាស្តុង ប៊ូធុល (Gaston Bouthoul) ជាសង្គមវិទូនិងប្រវត្តិវិទូជាតិបារាំង បានចាត់ទុក ''សង្គ្រាម,, ជាបាតុភូតមួយដ៏សំខាន់ មាននាទីជាអ្នកធ្វើឲ្យសារប្រែបទៀងនូវសមតា (l'équilibre) ក្នុងសង្គមមនុស្សទាំងឡាយនៃពិ-ភពលោក ។

# នៅឥណ្ឌូចិន បណ្ដាជនខ្មែរអាចទប់ នឹងបណ្ដាជនយួននិងសៀមបានឬទេ ?

ដើម្បីយល់ឲ្យបានច្បាស់លាស់ គួរចងចាំនូវគ្រោះថ្នាក់ជាអចិន្ត្រៃយ៍ ដែលគំរាមកំហែងប្រទេសកម្ពុជា ក្នុងអនាគតកាលខាងមុខនេះ យើងត្រូវពិនិត្យមើលស្ថានភាពប្រវត្តិសាស្ត្រជាក់ស្ដែង (Situation de fait) ខ្លះទុកជាគោលដៅជាបឋម ។ ក្នុងការវិភាគជាហូរហែមកហើយ ក្នុងប្រវត្តិសាស្ត្រនៃប្រទេសទាំងបី ខ្មែរ សៀម យួន ទំនាស់ខ្មែរ សៀម, រួចទំនាស់ខ្មែរ-យួនហើយចុងក្រោយបង្អស់គឺទំនាស់សៀម-យួន ជាព្រឹត្តិការណ៍មួយមានលក្ខណៈជាអចិន្ត្រៃយ៍ (Une permanence historique) ក្នុងប្រវត្តិសាស្ត្រនៃប្រជាជាតិឥណ្ឌូចិន អស់កាលច្រើនសតវត្សរួចមកហើយ ។ ប្រទេសសៀមជាប្រជាជាតិមួយ



ប្រកបដោយយុវភាព ( ប្រទេសសៀមចាប់កំណើតឡើងនាសតវត្សទី១៤) ក្រោយពីបានកាត់ទឹកដីលើផែនដីខ្មែរមួយភាគយ៉ាងធំនៅប៉ែកខាងជើង និងខាងលិច ប្រទេសកម្ពុជាបច្ចុប្បន្ន រួចហើយក៏បានចិត្តទុកនូវនយោបាយប្រពាក់ប្រពាញប្រទេសខ្មែរ ឲ្យចូល ទៅក្នុងការគ្រប់គ្រងផ្លូវនយោបាយរបស់សៀម គឺ ធ្វើប្រទេសខ្មែរឲ្យទៅជាអាណាព្យាបាលសៀមតែម្ដង (Faire du Cambodge un protectorat siamois) ដើម្បីទុកដែនដីនេះ ជាទ្រនាប់ទប់ទល់ នឹងការរាតត្បាតរបស់សត្រូវពីមួយទៀតគឺយួននេះឯង ។ ដូច្នេះទំនាស់សៀម-ខ្មែរមានលក្ខណៈជាជម្លោះរវាងប្រជាជាតិក្មេង និងប្រជាជាតិបុរាណមួយ.. ហើយជាការបង្កការប្រយុទ្ធដែលមានយុវភាពតែងតែមានជាមួយ ប្រៀបទៅលើការប្រយុទ្ធមួយទៀតដែលមានតែយកចាស់ ។ ហេតុនេះហើយបានជាយើងបាត់បង់អស់កាលណាខេត្តជាច្រើន ។ ផ្ទុយទៅវិញជនជាតិយួន ក្នុងដំណើររបស់ខ្លួនចុះមកចំសមានតែស្ទើរតាមបណ្ដោយឆ្នេរសមុទ្រខាងនិង

កម្ពុជាក្រោម មានគោលបំណងនឹងកាត់កាត់យកផែនដីក្រលឹង វៀតណាម គឺមិនមែនគ្រាន់តែចង់យកអាណាចក្រខ្មែរ ធ្វើជាផែនដីអាណាខេត្តយួនទេ តែមានបំណងបំបាត់សាសន៍ខ្មែរ សូន្យពូជខ្មែរ, គោលគិតធ្វើប្រទេសខ្មែរឲ្យក្លាយទៅជាផែនដីថ្មី របស់យួននេះនៃវៀតណាម ។

នេះហើយជាហេតុការណ៍ ដែលអាចពន្យល់យើងឲ្យយល់នូវនយោបាយយួន ដែលបានប្រព្រឹត្តមកលើជនជាតិខ្មែរ នៅសតវត្សរ៍ទី ១៨-១៩ និងនៅសតវត្សរ៍ទី ២០ ក្នុងផែនដីកម្ពុជាក្រោមសព្វថ្ងៃនេះ ។ បុព្វហេតុដ៏ជម្រៅ នៃនយោបាយភ្ជៀតយកដីយួន នៅផែនដីស្ដុកចិន គឺការណ៍នចំនួនបណ្ដាជនយួន ហើយនឹងគន្លះខាតផែនដីដែលមានដីជាតិសម្រាប់ចិញ្ចឹមបណ្ដាជនដែលរីកចំរើនយ៉ាងឆាប់រហ័ស ។ គួរឲ្យកត់សំគាល់ផងដែរថា ក្នុងការ "ហែកដីខ្មែរបែកគ្នា", នេះហើយដែលសៀមនិងយួនប៉ះទង្គិចគ្នា ឯការប៉ះទង្គិចគ្នានេះក៏មានជាហូរហែរួចមកហើយដែរលើផែនដីលាវ ។ ជនជាតិ



សៀមក៏ខានតែមានការមិនចុះចាញ់ឡើង ចំពោះគូសត្រូវថ្មីឈ្មោះនេះឯង ។ ក្នុងករណីនេះ ក្នុងពេលគ្រាកាលបើសៀមនិងយួនបានឈ្លោះគ្នាពី នៅលើទឹកដីខ្មែរ ប៉ុណ្ណោះវៀតណាម ។

X

X X

# ១៥.០០០.០០០ នាក់ដល់ គ.ស. ២០០០ !

យើងបាននិយាយជាស្រួសៗរួចមកហើយ អំពីផែនដីភូមិភាគខ្លះក្នុងពិភពលោកយើងនេះ ដែលបានស្គាល់នូវកំណើនបណ្ដាជនជាអតិបរមា ស្របតាមផលវិបាកនៃព្រឹត្តិការណ៍នេះទៀតផង ។ យើងក៏អាចពិចារណាដល់ផលវិបាកបែបនេះដែលនឹងអាចកើតមានឡើង នៅលើភូមិភាគឥណ្ឌូចិន បើប្រសិនជាការកើនបណ្ដាជននៅលើផែនដីនេះមានលក្ខណៈធម្មតា (un évolution normale) គឺជាបើគ្មានសង្គ្រាមឬអសន្តិសុខ ឬព្រឹត្តិការណ៍ផ្សេងទៀតមកធ្វើឲ្យស្ថានភាពនៃការកើនខាងនេះផ្លាស់ប្ដូរទេ ។

ដែលយើងរំពឹងដល់បញ្ហានេះ មិនមែនយើងយល់សប្ដិទេ. គឺយើងនិយាយក្នុងឋានៈជាមនុស្ស ដែលមាន



សម្បជញ្ញៈគ្រប់គ្រាន់ជាមនុស្ស «ធម្មតា» ដែលពិចារណារកហេតុផល ។

យើងគណនាតែត្រួសៗលើចំនួនបណ្ដាជនខ្មែរយើង ក្នុងឆ្នាំ ២.០០០ បាន ដោយយកអត្រានៃកំណើនបណ្ដាជន( le taux d'accroissement démographique) ២,៨ ឬ ២,៦ ភាគរយ (១) មកធ្វើមូលដ្ឋាន ។ ហេតុដូច្នេះយើងគណនាតាមវិធីវិទ្យាសាស្ត្រថា ក្នុងឆ្នាំ ២ ០០០ បណ្ដាជនយើងនឹងឡើងទៅដល់១៤ ឬ ១៥លាននាក់ហើយ ប្រសិនបើគ្មានសង្គ្រាមលោកឬអសន្តិសុខណាមួយ មករំខានការកើននេះទេនោះ ។ ឯចំនួនបណ្ដាជនយើងនឹងឡើងទៅដល់៨០នាក់ក្នុង១គ.ម.ការេ ។ បើយ៉ាងនេះមែន យើងអាចសន្និដ្ឋានបានថា ក្នុង៣០ឆ្នាំទៀតផែនដីយើងមិន

---

(១) យោងទៅតាមស្ថិតិឆ្នាំ ១៩៦២, អត្រានេះមាន ២,៣% [illegible] ២,៨%ឬ២,៦% នេះជា [illegible] (Les facteurs de croissance démographique au Cambodge thèse de doctorat de 3e cycle, Sorbonne Paris 1967).

ខានបង្កៀតបង្អួលទៅឡើយទេ ។ ម្យ៉ាងទៀតដែនដីយើងជាកាលពីដើម សម្បូរទៅដោយជលផល ហេតុនេះមនុស្សជាដើម, យើងនឹងអាចធ្វើរបៀបការងារកម្មកសិកម្ម ( méthodes d' exploitation agricole ) រីតតែប្រសើរឡើង ដោយធ្វើឲ្យសម្រេចនូវការបាចទឹកបញ្ចូលស្រែ (l'irrigation) ឯដីដាំដំណាំយើងនៅសេសសល់ច្រើន ។ សព្វថ្ងៃនេះដីដាំដំណាំយើងមានតែ១៨ % នៃផ្ទៃក្រឡាដីទាំងអស់តែប៉ុណ្ណោះ ។ យើងនឹងអាចបង្កើនទៅទៀត បើបណ្ដាជនយើងកើនច្រើនឡើង ៗ ។

ហេតុដូច្នេះយើងសង្ឃឹមថា ដែនដីយើងមិនខានបង្កៀតបង្អួលទេ ក្នុង ៣០ ឆ្នាំ ឬ ៤០ ឆ្នាំខាងមុខនេះ, យើងនឹងអាចពង្រីកផលិតផលកសិកម្មថែមទៀត ។ ព្រោះថាក្នុងអនាគតកាល មធ្យោបាយបច្ចេកទេសយើង គឺការនៃមានលក្ខណៈប្រសើរឡើងជាហូរហែ ។ យើងនឹងមិនខ្វល់ចំពោះអនាគតយើង ព្រោះប្រទេសយើងនឹងអាចចិញ្ចឹម



ដោយគ្រប់គ្រាន់នូវបណ្ដាជនរបស់យើងបានជាប្រាកដ ។ ប្រទេសយើងមិនជាបាច់នឹងអន្ទះអន្ទែង និងយោបាយពង្រីកទឹកដីខ្លួនទៅលើប្រទេសជិតខាងឡើយ ។

តែការដែលយើងគួរភ័យបារម្ភ គឺយើងត្រូវសួរខ្លួនយើងថា : តើអ្នកជិតខាងយើង, ខាងកើត យើងក្ដី ខាងលិចយើងក្ដី, នឹងទុកឲ្យយើងស្គាល់សន្តិភាពជារៀងរហូតឬ ? បើ៣០ ឬ ៤០ឆ្នាំទៀត ដែនដីរបស់គេនឹងពេញព្រៀប, ប្រៀបបាក់ដូចជាទឹកដែលពេញល្អាងទៅហើយៗ ហូរហៀរចេញមកក្រៅ ក៏ប្រជែងទៅកាន់ទីទំនាបដទៃទៀត ។ តើយើងត្រូវគិតទុកថា ទីទំនាបដែលមិនទាន់ដក់ទឹកទាំងនេះ មានវាលបន្ទាបមាត់ទន្លេមេគង្គនិងទន្លេសាប (la vallée du Mékong) ពោលគឺប្រទេសកម្ពុជាយើងអាចជៀសផុតពីគ្រោះថ្នាក់នេះឬ ?

x

x x




"ដំណើរសម្រុកចុះមកទិសខាងត្បូង"
-111 មុនគ.ស. ដល់ 1840
តើយួនសម្រុកទៅទិសណាទៀត?

# គ្រោះថ្នាក់របស់យើងនៅទិសខាងកើត ជាង ៨០.០០០.០០០ នាក់រស់នៅលើផែនដីមួយ យ៉ាងចង្អៀតចង្អល់

នៅទិសខាងកើត ដែនដីប្រទេសកម្ពុជាយើង. ជនជាតិយួនបានចុះសម្រុកមកពីទិសខាងជើង តាមឆ្នេរសមុទ្រពីនគរចាម្ប៉ា ហើយបានធ្វើការទន្ទ្រាន លុកលុយដណ្តើមដីធ្លី ពីដូនតាយើងកាន់តែចុះសម្រុកទៀត ចាប់ពីរ៉ូរ៉ា ក្រោយពីកន្លងរយៈ ១៥០ ឆ្នាំជាយតែប៉ុណ្ណោះ យួនបានមកកាន់កាប់ ព្រមទាំងក្លាយខ្លួនទៅជាម្ចាស់ទឹកដី កម្ពុជាក្រោមទាំងស្រុងដាច់ស្រេច (ក្នុង គ.ស.១៨៤០) ។ គួរតែយើងចាំទុកថា ជនជាតិយួនទាំងនេះដែលបានលេបស៊ីទឹកដីយើងមួយភាគយ៉ាងធំ មានទំហំ ៦៤.០០០ គ.ម. ក្រឡាស្មើនឹង

ប្រទេសលង្កា(Ceylan) ទាំងមូលនេះបាន ក៏ដោយសារសម័យ
នោះបណ្ដាជនយើងនៅកម្ពុជាក្រោម មានចំនួនតិចពន់ពេក
ណាស់ ថ្វីបើផែនដីតំណែលដូនតាយើងនេះ ជាផែនដីមួយ
ដែលប្រកបទៅដោយជីជាតិ ដ៏វិសេសវិសាលរកដីឯណា
មកប្រដូចពុំបានឡើយក៏ដោយ ។

ចំណែកឯការដែលយួនសម្រុកចុះមកកាន់ត្បូងនេះបណ្ដាល
មកពីបុព្វហេតុថា បណ្ដាជនកើតច្រើនពេក យួនពុំអាចមាន
ដីល្អគ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្នាគេបានឡើយ ។ ហេតុ
នេះហើយបានជាយួនបានផ្ដើមនយោបាយពង្រីកទឹកដីខ្លួនមក
លើកជាណាបក្រៅខាងត្បូងឥតឈប់ឈរ ហូតដល់សម័យបច្ចុប្បន្ន
កាលនេះទៀត ក៏យួនពុំព្រមបញ្ឈប់អំពើលួចចូលមកតាំងនៅលើដី
ដែលទំនេររបស់យើងឡើយ ។

សព្វថ្ងៃនេះ ប្រទេសវៀតណាមមានផ្ទៃក្រឡាប្រហែល
៣៣០ ០០០ គ.ម² គឺធំជាងប្រទេសយើងចំនួនជិត ២ ដង ។
គឺជាប្រទេសមួយដែលមានបណ្ដោយដ៏វែង ចម្ងាយពីខាងជើង



មកត្បូងជិតតែ ២០០០ គ.ម. ។ ឆ្នាំ ១៩៧០ បណ្ដាជនទាំង
អស់នៃប្រទេសនេះ មានចំនួនជិតទៅ ៤០ ០០០.០០០ នាក់
គឺ ២០ លាន នៅប៉ែកខាងជើង និង ១៨ លាននៅប៉ែកខាងត្បូង ។
ប្រទេសវៀតណាម ជាផែនដីមួយសម្បូរទៅដោយព្រៃព្រឹក្សា
និងភ្នំ ។ ព្រៃនិងភ្នំនេះគ្របដណ្ដប់លើផ្ទៃដី ៨០% នៃផ្ទៃក្រឡា
ទាំងអស់ គឺស្មើនឹងផ្ទៃក្រឡា ២៦០ ០០០ គ.ម ខ្ទង់ណា ។
ហេតុដូច្នេះហើយបានជា, មនុស្សទាំង ៣៨ លាននាក់នេះ
រស់នៅលើផ្ទៃដីតែ ២០ ភាគរយតែប៉ុណ្ណោះ គឺស្មើនឹងផ្ទៃ
ក្រឡា ៦០.០០០ គ.ម. ខ្ទង់ណា ។ ក្នុងករណីក្រោយនេះ
ដង់ស៊ីតេ (densité) ឡើងទៅដល់ ៦០០ នាក់ ក្នុង ១ គ.ម² ។
ដូចយើងឃើញស្រាប់ សព្វថ្ងៃនេះ ដីប្រទេសវៀតណាម
នេះបានរៀតបន្តឹងណាស់ទៅហើយ ។ ចំណែកផលិតផលស្រូវ
អង្ករ ក៏ស៊ីរតែមិនគ្រប់គ្រាន់ផង ។ ជង្រុកស្រូវដ៏ធំនៃប្រទេស
នេះគឺដែនដីសណ្ដ (le Delta) នៃទន្លេមេគង្គ និងដីសណ្ដទន្លេ
ស៊ុងកៃ (le delta du Fleuve Rouge) ។ ផ្នែកដីសណ្ដទន្លេ

មេគង្គអាចផ្តល់ស្រូវអង្ករជាមធ្យម ៦.០០០.០០០ តោនក្នុងមួយឆ្នាំ ហើយដីសណ្តទន្លេសុងកៃផ្តល់ឲ្យ ៤.០០០.០០០ តោនជាមធ្យមដែរ ។ បូកទៅបានត្រឹមតែ ១០ លានតោនប៉ុណ្ណោះ, ដូច្នេះទៅថ្លៃម្ហូបស្រូវអង្ករនេះ ប្រាកដជាមិនអាចបំពេញសេចក្តីត្រូវការរបស់បណ្តាជនយួន ដែលកំពុងកើនចំនួនយ៉ាងលឿនណាស់ឡើយ ។

ក្នុងចំណោមប្រទេសអាស៊ីទាំងឡាយ យួនមានអត្រានៃកំណើនប្រជាជន (taux d'accroissement démographique) ខ្ពស់ជាងគេឯង[1]គឺមានរហូតដល់ទៅជាង ៣% ។ បើយោងទៅតាមភាគរយនេះ ក្នុងឆ្នាំ ១៩៧០ បណ្តាជនយួនរួមទាំងខាងជើងនិងខាងត្បូង នឹងឡើងដល់ទៅ៤០ ០០០.០០០នាក់ ។

---

(១) — យោងទៅតាមសៀវភៅ :— « Les Deux Viet-Nam, Bernard Fall , Payot Paris, 1967- »

បើតាមលោក B. Fall, អត្រានៃកំណើននេះ ឡើងដល់ទៅ ៣,៥%បើតាមស្ថិតិផ្លូវការជំរឿនប្រជាជនឆ្នាំ ១៩៦០ នៅប្រទេសវៀតណាមខាងជើង ។ ចំពោះវៀតណាមខាងត្បូង លោក. B . Fall និយាយត្រឹមតែ ៣ ភាគរយតែប៉ុណ្ណោះ ។



ក្នុងលក្ខណៈនេះ ប្រសិនបើការកើនរបស់ប្រជាជននេះ មានល្បឿន ទៅមុខទៀត ដោយគ្មានព្រឹត្តិការណ៍ធំដុំអ្វីមករំខានទេ បណ្តាជនប្រទេសវៀតណាម នឹងឡើងរហូតទៅ ជាង៨០.០០០.០០០ នាក់ ក្នុង ៣០ ឆ្នាំទៀត ។ ឯកម្ពុជាយើងដល់ឆ្នាំ ២០០០ មានត្រឹមតែ ១៩ លាននាក់ប៉ុណ្ណោះ ។

x

x x

## តើនឹងមានផលវិបាកធ្ងន់ធ្ងរអ្វីខ្លះ ?

- បើនឹកគ្រប់ចោទសួរដោយផ្ទាល់ថា ៖ តើដី ២០ ភាគរយ នៃផ្ទៃក្រឡាទាំងអស់ ៣៣០.០០៩គ.ម² ឬក៏ដីត្រឹមតែ ៦០.០០០គ.ម² ប៉ុណ្ណោះ អាចផ្តល់អាហារគ្រប់គ្រាន់ឲ្យដល់មនុស្សជាង ៨០ លាននាក់បានឬទេ ?

ឆ្លើយវិញភ្លាមថា៖ ត្រឹមតែសព្វថ្ងៃ ៦០ លានប៉ុណ្ណោះ ពិបាកនឹងចិញ្ចឹម ឲ្យបានស្បៀងអាហារគ្រប់គ្រាន់ទៅហើយ ចុះដល់ទៅ ៨០ ០០០.០០០ តើនឹងកើតជាបញ្ហាយ៉ាងណាទៅ?

តើប្រទេសវៀតណាមនឹងក្លាយទៅជា " ជប៉ុន " ទី ២ ក្នុងទ្វីបអាស៊ី ឬ អាល្លឺម៉ាញទ្វីបអាស៊ី ឬ ?

ឆ្លើយ ៖

● ទី ១ ឬមួយក៏ប្រទេសវៀតណាម នឹងពង្រីក



កម្លាំងឧស្សាហកម្មនិងសេដ្ឋកិច្ចជាតិបានជា ប្រៀបប្រដូចបានទៅនឹងប្រទេសជប៉ុនទី ២ ក្នុងអាស៊ីភាគអាគ្នេយ៍ ។ គំនិតនេះត្រូវបានអ្នកសង្កេតការណ៍អន្តរជាតិខ្លះ លើកយកពិគ្រោះជាមុនទៅហើយ គឺមុនការបញ្ចប់សង្គ្រាមវៀតណាមនេះទៅទៀត ។ ជាពិតប្រាកដមែនហើយ នេះគឺជាការប្រាថ្នាណាស់ ។ ប្រទេសវៀតណាមបច្ចុប្បន្នទៅហាក់ដូចជាមាន លោហធាតុ ថែមទាំងក្រុមអ្នកវិទ្យាសាស្ត្រ និងបច្ចេកទេស (techniciens, ingénieurs, chercheurs . . .) ប្រកបដោយចំនួនច្រើនគ្រប់គ្រាន់ ហើយមានបរិមាណទៀតផង ឬក្រុមមនុស្សក្នុងអា. គតជីជំរេជ ( ជាង ៨០លាននាក់ ), នឹងអាចក្លាយទៅពិតប្រាកដ ជាមហាអំណាចឧស្សាហកម្មយ៉ាងសំខាន់ក្នុងពិភពលោកបើមិនខានដូច្នេះ ។ កាលបើវៀតណាមក្លាយទៅជាឧស្សាហករហើយ ប្រទេសនេះអាចលក់ចេញទៅបរទេសនូវផលិតផលឧស្សាហកម្ម ដើម្បីអាចទិញប្តូរមកវិញនូវផលិតផលកសិកម្ម ដើម្បីការត្រូវការខាងចំណីអាហារនៅក្នុងប្រ

ទេសៗ គឺមានតែធ្វើយ៉ាងហ្នឹងទើបចណ្តាលប្រទេសនេះរួច រស់នៅបាន ដោយគេចៀសឲ្យផុតអំពីបញ្ហាសង្គម និងនយោ-បាយ ដែលនឹងកើតមានលក្ខណៈស្មុគស្មាញឡើង ។

ចូរយើងពិនិត្យមើលប្រទេសជប៉ុនដែលក្នុងបច្ចុប្បន្ន កាលនេះ មានផ្ទៃក្រឡាប្រហាក់ប្រហែល នឹងវៀតណាម ដែរ ( ៣៧០.០០០គ.ម² ) ហើយមានមនុស្សរស់នៅចំនួន ជាង ១០០ លាននាក់ទៅហើយ ។ ស្ថានភាពនៃប្រទេសនេះ ពុំខុសពីប្រទេសវៀតណាមប៉ុន្មានឡើយ ៖ ក្នុងដី ៣៧០ ០០០គ.ម² ដីត្រឹមតែ ១៦ ភាគរយប៉ុណ្ណោះ ដែល គេអាចដាំដំណាំ ហើយរស់នៅបានៗ ក្រៅពីនេះ គឺសុទ្ធសឹង តែភ្នំព្រៃព្រលងក្រំថ្មពុំអាចឲ្យមនុស្សរស់បានឡើយ ។ កាល ពីរកឆ្នាំ ១៩៣០ ជប៉ុនបានស្គាល់នូវកំណើនប្រជាជនមួយ យ៉ាងលឿន ហើយដើម្បីនឹងដោះស្រាយបញ្ហាខ្វះដីធ្លីនេះ ជប៉ុនបានអនុវត្តនូវនយោបាយពង្រីកទឹកដីនិយម ដោយវាត-យកឈ្លានពានដណ្តើមដែនដីពីប្រទេសចិន, ប្រទេសកូរ៉េ



។ល។ ប៉ុន្តែនយោបាយនេះបានត្រូវទទួលបរាជ័យក្រោយ សង្គ្រាមលោកលើកទី ២ បាត់ស្រុងទៅហើយ ។ ហេតុ នេះហើយ បានជាជប៉ុនកែប្រែនយោបាយរបស់ខ្លួនមកវិញ រហូតដល់ក្លាយទៅជាមហាអំណាចសេដ្ឋកិច្ចទី ៣ ក្នុងពិភព លោក ( 3ème puissance économique mondiale ) ក្រោយ ស.ស.ស ( សូវៀត ) ។

ដូចយើងឃើញស្រាប់ហើយ, លក្ខណៈទឹកដី និងភូមិ សាស្ត្រវៀតណាម និងជប៉ុនមានលក្ខណៈប្រហាក់ប្រហែល គ្នា ។ ដូច្នេះប្រហែលជាគ្មានកម្លាំងអ្វីអាចមកកាត់ មិនឲ្យប្រ-ទេសវៀតណាម ក្លាយទៅជាមហាប្រទេសសេដ្ឋកិច្ចបាន ឡើយ, ហើយផ្សារដ៏សំខាន់នៃសេដ្ឋកិច្ចឧស្សាហកម្មនេះ គឺ ដែនដីអាស៊ីប៉ែកអាគ្នេយ៍តែម្តង ។ល។

បើប្រសិនយ៉ាងនេះមែននោះ ប្រទេសកម្ពុជាយើងនឹង ត្រូវទទួលរងគ្រោះថ្នាក់ធំ និងមិនអាចគេចផុតបានឡើយ ក៏ ពីកម្លាំងវៀតណាមនេះ ព្រោះការវិវត្តន៍ត្រូវតែយ៉ាងដូច្នោះ

ចំពោះយើង បើសេដ្ឋកិច្ចនៅតែខ្សោយ យើងនឹងក្លាយទៅជាផ្សារសេដ្ឋកិច្ចយួនតែម្តង ។ នេះហើយជាទិដ្ឋភាពថ្មីមួយទៀតនៃលទ្ធិអាណានិគមនិយមសម័យថ្មី ដែលមានភាពសាហាវ មិនខុសពីអាណានិគមនិយមបុរាណ ឬ ទឹកដីនោះសោះឡើយ ។ នេះគឺរបៀបម្យ៉ាងដែលនឹងនាំប្រទេសយើងឲ្យធ្វើដំណើរ ឆ្ពោះទៅរកការបាត់បង់ឯករាជ្យជាតិដែរ ។

តែក្នុងរយៈពេលសព្វថ្ងៃនេះក៏ដោយចុះ កុំតែយើងប្រយ័ត្នបារម្ភទុកឲ្យហើយ ព្រោះគ្រាន់តែវៀតណាមខាងត្បូងចំណោះបញ្ជូននិស្សិតនោះទៅបរទេសក្នុង មួយឆ្នាំ រាប់ពាន់(១)នាក់ ឲ្យទៅសិក្សាឧត្តមវិជ្ជានៅក្រុងប៉ារីស ។ ឯ វៀតណាមខាងជើងវិញ និស្សិតបច្ចេកទេស ស្ទើរតែរាប់ពាន់នាក់ ត្រូវបញ្ជូនទៅរៀននៅសហភាពសូវៀតនិងក្រុងប៉េ

(១)- យោងទៅតាមសៀវភៅលោក B.Fall, « Les deux Vietnam Payot, 1967 , Paris, ទំព័រ (៣៦១)



ប៉ែកខាងកើតនិងនៅប្រទេសចិន ។ល។ ទាំងក្រុមៗ តែម្តងៗ លុះដល់សង្គ្រាមបញ្ចប់ភ្លាម ប្រទេសកុម្មុយនិស្តទាំងឡាយ នឹងនាំគ្នាជួយកសាងសេដ្ឋកិច្ច ឧស្សាហកម្ម កសិកម្មប្រទេសនេះឡើងវិញ ។ ការជួយនេះជាកាតព្វកិច្ចសំខាន់ណាស់ ព្រោះប្រទេសកុម្មុយនិស្តទាំងឡាយ រមែងតែងមាន សេចក្តីសាមគ្គីគ្នាយ៉ាងជិតស្និទ្ធ ក្នុងគំនិតអន្តរជាតិនិយមប្រូលេតារ ( dans l' intérêt de l'internationalisme prolétarien) ។

ម្យ៉ាងទៀត សង្គ្រាមនៅវៀតណាមខាងត្បូង មិនទាន់បញ្ចប់ស្រេចបាត់ផង ស្រាប់តែមូលធនបរទេស មានជប៉ុនដើមនេះ រួមមានហុងកុង ការ៉េ សិង្ហបុរី ចូលមកធ្វើវិនិយោគ (investissements) យ៉ាងគគ្រឹកគគ្រេងក្នុងប្រទេសនេះនៅហើយ . . . ចុះចំពោះសង្គ្រាមបញ្ចប់ទៅ តើមូលធនបរទេសនឹងហូរចូលមកយ៉ាងណាទៀតទៅ ? ចំណែកខាងវៀតកុងវិញ ប្រាកដជាមិនបែងចាកចេញពីប្រទេសវៀតណាមដោយទុកឲ្យប្រទេសនេះធ្លាក់តែការខ្វះខាតយ៉ាងដូច្នេះទេ, បើពុំ

នោះ ស.រ.អា. នេះនឹងត្រូវអាម៉ាស់មុខ យ៉ាងអាណោចអាធម្ម ចំពោះមតិសាធារណជនពិភពលោក ។ អាមេរិកត្រូវរលុបលាងកិត្តិយសរបស់ខ្លួន ។ ក្នុងឆ្នាំ ១៩៦៩ គង់នៅហើយនេះ សហរដ្ឋអាមេរិកបានតាំងគ្រោងថវិកាចំនួន៦ ០០០ ០០០ ០០០ ដុល្លារ ( គឺត្រូវជាប្រាក់រៀលជាង ១០០ កោដិ ) សំរាប់ស្ថាបនាប្រទេសវៀតណាមឡើងវិញ ។

ហេតុដូចខាងលើនេះហើយ បានជាបណ្ដាអ្នកសង្កេតការណ៍ខ្លះជាតិខ្លះបានយល់ថា ៖ ការរួបរួមគ្នាឡើងវិញ នៃប្រទេសវៀតណាម ជាមហន្តភ័យឥតអ្វីប្រដូចបានចំពោះអត្ថិភាព នៃមាតុប្រទេសកម្ពុជាយើង ។

បើប្រសិនជាយ៉ាងនេះមែន តើយើងនឹងអាចមានវិធីការទប់ទល់នឹងកម្លាំងសេដ្ឋកិច្ចយួនកុំឱ្យក្លាយមក លេបសេដ្ឋកិច្ចយើងបានទេ ? បើមិនបានទេនោះ , តើរក ៣០ ឆ្នាំទៀត យើងនឹងគង់ស្ថិតនៅបន្តទៅទៀតបានឬទេ ?



ចំពោះកម្ពុជាយើង មានតែមាគ៌ាមួយគត់សម្រាប់ការដោះស្រាយឱ្យបានគង់វង្សជាតិ ។ មាគ៌ានោះ, គឺការពង្រឹងកម្លាំងសេដ្ឋកិច្ចយើង ឱ្យមានល្បឿនជាប់រហ័សជាងកាលសម័យ ក្រែងអាចទប់ទល់បានខ្លះ នូវកម្លាំងសេដ្ឋកិច្ចយួននេះ ។ ការបណ្តែតឱ្យយឺតយ៉ាវតទៅទៀត គឺជាអំពើអត្តឃាតកម្ម, គឺជាកំហុសដ៏ធំណាស់ចំពោះប្រវត្តិសាស្ត្រ របស់មាតុភូមិជាទីស្នេហានៃយើងទាំងអស់គ្នា ។ ប្រវត្តិសាស្ត្រមានភ្នែក ។ ប្រវត្តិសាស្ត្រនឹងដាក់ទោស មកលើយើងទាំងអស់គ្នាដែលធ្វេសប្រហែសក្នុងបញ្ហានេះ ។

ទី ៦– ឬមួយក៏ប្រទេសវៀតណាម នឹងអនុវត្តនយោបាយបន្ថយចំនួនកូនកុំឱ្យ កើតច្រើនពេក ( limiter les naissances) ការនេះអាចនឹងសម្រេចបាន ក៏ស្រេចនៅលើការយល់ឃើញនៃអ្នកនយោបាយយួនក្នុងអនាគតតែប៉ុណ្ណោះ ។ បើ

ទុកណាជានយោបាយជាយថាហេតុបែបនេះ អនុវត្តទៅប្រកប ដោយជោគជ័យក្តី, គឺចំនួនបណ្តាជនទៅច្រើនជាងគេ ។ ប្រាកដសរ វៀតណាមនៅតែពង្រីកកម្លាំងសេដ្ឋកិច្ច ទស្សន- កម្មវិធីពេះព្រោះនេះជាកាតព្វកិច្ចខាងពុំបាន ។ ហេតុដូច្នោះ គ្រោះថ្នាក់នៅតែមានលក្ខណៈធ្ងន់ធ្ងរដែល មកលើកសា ខែន កម្ពុជាយើងទៅអនាគត ។

ង ៣ - តែបើប្រសិនជាផ្ទុយទៅវិញ កម្លាំងសេដ្ឋកិច្ច វៀតណាមពុំបានល្អគួរសម គ្រប់គ្រាន់ទេនោះ ហើយ នយោបាយបន្ថយកំណើតកូនចៅ កំពុងត្រូវបានអនុវត្តទៀត នោះមហាក្ខកយើងនៅតែមានចំហាំគុណាពីវេង . . . ដដែល ។ល។ ទាំងណាស់ទៅទៀតមកលើអនាគតប្រទេសកម្ពុជាយើង ។

ហេតុដូចម្តេចបានជាការនេះកើតជាយ៉ាងដូច្នេះទៅវិញ ?

„សង្គ្រាម„ និង „ភាព„ ផ្ទុះឡើងរវាងខ្មែរនិងយួន ពិបាកនឹងជៀសវាងបាន ព្រោះបណ្តាជនយួនកាន់តែកើនឡើង ជាលំដាប់លំដោយ ៥០-៦០-៧០ ៨០ ៩០លាននាក់ ក្នុង



៣០ឆ្នាំទៀត ។ ឯធនធានខាងសេដ្ឋកិច្ច និងវាទីកសិកម្ម នៅដដែលឬលូតលាស់យឺតរោគ ជាហេតុពុំអាចនឹងអនុញ្ញាត ឲ្យចិញ្ចឹមមនុស្សបានក្នុងភាពគ្រប់គ្រាន់ឡើយ ។

ការនេះនឹងបង្កើតឲ្យមានវិបត្តិផ្ទៃសង្គម-រួចវិបត្តិផ្ទៃនយោ បាយ បង្កើតឡើងដោយសេចក្តីមិនសប្បាយចិត្ត ប្តូរការ ក្រៅខ្ខាតរបស់ជនជាតិយួននោះឯង ។ ពេលនោះហើយ, នឹង មានអ្នកនយោបាយយួនខ្លះ ដែលជាអ្នកជាតិនិយមហួសហេតុ (Les Vietnamiens Ultra-nationalistes) បង្កបង្កើតឲ្យមាន ទ្រឹស្តី ពង្រីកទឹកដីនិយមតាមរបៀបអាល្លឺម៉ាញជំនាន់ហ៊ីត្លែរ (Hitler) តាមការត្រូវទឹកដីមួយដែលគេនឹងសន្មត់ថាគ្រប់គ្រាន់ សម្រាប់ការរស់នៅរបស់ប្រជាជនគេ (une nouvelle théorie de l'Espace Vital) ។ ហើយផែនដីដែលគេត្រូវការនោះ គឺ មានតែកម្ពុជា-លាវ-ឬសៀម(?) តែប៉ុណ្ណោះ ។ ដើម្បីនឹង សម្រេចនូវផែនការនេះបាន , នយោបាយឈ្លានពានបង្ក រឿងហេតុ ឲ្យកើតទៅជាសង្គ្រាមឥណ្ឌូចិន „ទី៣„(?)

គេពុំអាចនឹងជៀសវាងបានឡើយ ។

បើយ៉ាងនេះមែន នៅពេលដែលមេឃនៃអាកាសនៃផែនដីណា មិនមានគត់តែទៅវិញទៀត មកបំបាត់សេចក្តីសង្ឃឹមរបស់យើងឲ្យរលត់រលាយសូន្យ គួរឲ្យស្រណោះអាណោចអាធ្រមក្រៃពេក ។

ប្រសិនបើនយោបាយពង្រីកទឹកដីនិយម ដើម្បីរស់នេះត្រូវគេអនុវត្តមែនទែន ដែនដីយើង បណ្តាជនយើងនឹងត្រូវគេលេបបន្តិចម្តង ៗ ហើយទីបំផុតនឹងលាយឡំ បាត់ឈ្មោះចេញពីផែនទីនៃពិភពលោក ដូចប្រវត្តិសាស្ត្រនៃអាណាចក្រចម្ប៉ា ឬដែនដីកម្ពុជាក្រោម ឥតបើប្រកែកបានឡើយ ។

ពីពេលនេះទៅហើយ ដែលប្រវត្តិសាស្ត្រ នឹងថ្លែងគំនិត « ដំណើរឆ្ពោះទៅទិសខាងលិច » នៃប្រជាជាតិយៀកណាម ក្រោមសន្ទុះនៃកំណើនជាតិសាសន៍នៃបណ្តាជនមួយ ដែលឃ្លាំចាំទុកសម្រាប់លេបដីនៃយើង អស់រយៈកាលច្រើនសតវត្សមកហើយ ។



រួមសេចក្តីៈ ដែនដីណាមិនជាដែនដីមួយដែលខ្វះស្ថាភាពជានិរន្តរ៍ ។ នៅលើដែនដីនេះប្រទេសកម្ពុជាយើងគង់មានតទៅកាលខាងមុខនេះ នឹងត្រូវទទួលរងគ្រោះថ្នាក់ដ៏ធំធេងច្រើនថែមយ៉ាង ដូចជាការគំរាមកំហែងដល់ការគង់វង្សជីវិត (la survie) នៃប្រជាជាតិយើងទៀតផង ។ បើទុកជាការវិវត្តន៍ នៅប្រទេសយៀកណាមទៅជាយ៉ាងណាក៏ដោយ, មហន្តរាយគ្រប់បែបនៅចាំយាយីជាតិយើងគ្រប់ជំហាន ។ ពេលវេលាដើរលឿនទៅមុខឆ្ងាយទៅ ៗ មហន្តរាយក៏លេចរូបកាន់តែច្បាស់ឡើង ៗ ជាលំដាប់ដែរ ។

គឺមានតែនយោបាយ ពង្រីកកម្លាំងសេដ្ឋកិច្ចជាតិឲ្យបានឆាប់រហ័សប៉ុណ្ណោះទេ ដែលអាចឲ្យយើងមានមធ្យោបាយទប់ទល់នឹងយថាហេតុគ្រប់បែបយ៉ាងបាន ។ . . . តែនេះគ្រាន់តែជានិក្ខេបបទ ( des thèses ) ជាទ្រឹស្តី ឬ ជាមតិ (l'opinion) របស់មនុស្សម្នាក់តែប៉ុណ្ណោះ ដូច្នេះពុំទាន់ចាត់ទុកជាត្រឹមត្រូវបានការពេញលេញនៅឡើយទេ ។ ឯការពិតស្ថិតនៅលើ

ប្រវត្តិសាស្ត្រគង់តែតាមកាលឯនោះវិញទេ ដែលគាបចិត្តជួយ

បាន . . . ។

ក៏ប៉ុន្តែ យើងមិនមែនមានតែ « យួន » ទេដែលយាំយី

ប្រលើយ នៅឯទិសខាងលិច « សៀម » ក៏ចាំតែឱកាសល្អនឹង

« ក្រញែប » ដែនដីរបស់យើងដូចគ្នាដែរ ។

x

x x



# ប្រទេសសៀមនឹងមានបណ្តាជន ៧០ លាននាក់

នៅពីខាងជើង និង ខាងលិចប្រទេស កម្ពុជាយើងបណ្តាជនប្រទេសមួយទៀត នឹង អាចក្លាយទៅជាគម្រាមដ៏ធ្ងន់ មួយដ៏ទៀត សង្កត់មកលើដែនដីយើង . . . ។

កាលបើយើងបានលើកបញ្ហាយួន មកពិចារណាឲ្យល់ ច្បាស់លាស់សព្វគ្រប់ ជាតិយើងរួចហើយ យើងពុំគប្បីភ្លេចបាន សោះឡើយថា គ្រោះថ្នាក់ដែលនឹងគំរាមយាយីមកប្រទេស ខ្មែរយើង មិនមែនបានមកតែពីទិសខាងកើតនៃខាង តែប៉ុណ្ណោះឡើយ, នេះគឺ « សត្រូវ » ចុងក្រោយរបស់ យើង ដែលបានលេបរួចមកហើយនូវដែនដីយើង ដែលមាន ផ្ទៃក្រឡាជាង ៦០.០០០គ.ម² ស្មើនឹងក្រឡាផ្ទៃប្រទេសអ៊ី ស្រាអែលបីដង ។ យើងនៅមានអ្នកជិតខាងរបស់យើងមួយ ទៀត ដែលជា « សត្រូវ » ចាស់ពីបុរមបុរាណ ហើយដែល

បានគ្រប់គ្រងលេច ជាច្រើនសតវត្សមកហើយ ឥឡូវណា ខែក្រោយរបស់យើងច្រើនតែគេ ៖ « សត្រូវ » នេះ, ដែលយើងមិនទាន់តាមចាប់ភ្លេចបានជា មុនឆ្នាំ ១៩០៧ បានយកភាគទៅតាំង នៅលើ ១/៣ នៃដែនដីយើងសព្វថ្ងៃនេះ ហើយដែលកាលពីឆ្នាំ ១៩៤១ ដល់ ១៩៤៥ បានមកចង្វាក់ដណ្តើមតាមវិធីកម្លាំង បាយខ្លួនខេត្តសៀមរាប, កំពង់ធំ, បាត់ដំបង, ជាលាថ្មីទៀត, ពីប្រទេសសៀម ឬ ថៃឡង់នេះឯង ។

បើនៅក្នុងពង្សាវតារខ្មែរយើង ផងជាតិយួន ជាផងជាតិប្រកបដោយគ្រោះថ្នាក់ យ៉ាងជាក់ស្ដែងចំពោះយើងយ៉ាងណា ផងជាតិសៀមក៏ជាអ្នកជិតខាងប្រកបដោយគ្រោះថ្នាក់ដែលមានសភាពសាហាវមិនចាញ់គ្នាយ៉ាងនោះដែរ ។

ដូច្នេះហើយ , ការដែលយើងចាប់អារម្មណ៍ទៅលើគ្រោះថ្នាក់ទាំងពីរនេះព្រមគ្នា ជាមធ្យោបាយតែមួយគាចឲ្យយើងប្រុងប្រៀបដំណើរការណ៍ទុកជាមុនឲ្យហើយ នេះព្រោះជា ១ភ្លូមកកដ៏ប្រសើរ វិសេសវិសាលក្រៃលែង



ណាស់ទៅហើយ ប្រវត្តិសាស្ត្រពីគតិកាលថ្មី ១ នេះជាមេរៀនប្រាប់ , ការដែល « ចាំទឹងធីការជឿងដល់ប្រមុះ » , សិមប្រើប្រាស់គេទីដម្រេក នឹងក្លាយទៅជាសេចក្ដីផ្ដើមនៃការលេចលង់ចុងបំផុតនៃភាគអស់សង្ឃឹមមិនខានឡើយ ។

x

x x

# តើបណ្ដាជនសៀមអាចនឹងមានឥទ្ធិពលអ្វីខ្លះលើអនាគតនៃដែនដីរបស់យើង

ជាម៉ូយក្នុងកាលត្រឹមត្រូវមួយរយៈកាលយូរ តបទៅសំណួរនេះវិញ, គ្មានជនណាមួយតបភ្លាមបានឡើយ តែគេតបតែសេចក្ដីសន្និដ្ឋានក្នុងការប្រហាក់ប្រហែល មានបែបផែនជានិក្ខេបបទ ( des thèses ) បានខ្លះៗ ។

តាមឯកសារសរសេរដោយលោកឡាលូបែរ ( La Loubère) ក្នុងឆ្នាំ ១៦៨៣ បណ្ដាជនសៀមមានត្រឹមតែ ១.៩០០.០០០ នាក់តែប៉ុណ្ណោះ ។ ជាងមួយសតវត្សក្រោយមកទៀតគឺក្នុង គ.ស ១៨៥១, បណ្ដាជននេះកើនដល់ទៅ ៥.២០០.០០០ នាក់ ( នៅរយៈពេលប្រហែលគ្នានោះ ខ្មែរយើងមានប្រហែល ៨០០.០០០ នាក់ ) ។ រួចហើយ បណ្ដាជននេះកំកើនចំនួនទៅជា ៨.២០០ ០០០ នាក់នាឆ្នាំ ១៩១០, រួច ១៤.៥០០ ០០០ នាក់នាឆ្នាំ ១៩៣៧, រួច ២២ ៨០០.០០០



នាក់នាឆ្នាំ ១៩៥៦ ។ គ្រាន់តែក្នុងឆ្នាំ ១៩៦៧តែប៉ុណ្ណោះ បណ្ដាជននេះ កើនដល់ទៅ ៣០ លាននាក់ ស្រេចទៅហើយ ។ តាមការគន់គូរ តាមរបៀបវិទ្យាសាស្ត្រ ដល់ឆ្នាំ ១៩៧៥ ខាងមុខនេះ គឺនឹងឡើងទៅដល់ ៤០ លាននាក់[9] ។

ដូចជាយើងបានឃើញនេះស្រាប់ បណ្ដាជនសៀមកើនលឿនរហ័សជាពន់ពេក ហើយគេនឹងសេសសល់ទៅទៀត គឺតាំងពីក្រោយសង្គ្រាមលោកលើកទីពីរមក ។

កំណើនដ៏លឿននេះ បណ្ដាលមកពីការចុះថយដ៏ច្រើននៃចំនួនមនុស្សស្លាប់ក្នុងមួយឆ្នាំ ៗ (baisse du taux de mortalité) ហើយថយទៅវិញចំនួនមនុស្សកើត គាំនៃតមានសន្ទុះលឿនទៅមុខឥតឈប់ឈរ ។ មុនឆ្នាំ ១៩៥០

---

(9) ដោយយោងតាមសៀវភៅ «l' Evolution de la Thailande contemporaine» Cahier de la Fondation Nationale des Sciences, Politiques. P.Fistié. Paris. 1967.- et «la Thailande» de Q.S.J. P.U.F. Pasis. 1963.

គេបានគិតទុកប្រមាណទសវត្សន៍នេះ ជាប្រជាជាតិដែលសម្បូរសប្បាយសេក្ដីសេចក្ដី « ស្ងប់ស្ងាត់ » គ្មានបញ្ហាចោទសោះឡើយ ។ ឥឡូវនេះ . អស់ហើយភាពសម្បូរសប្បាយ អស់ហើយភាព « ស្ងប់ស្ងាត់ » បញ្ហាដ៏ច្រើនសែនកំពុងតែចោទឡើង គឺមូលហេតុនៃបញ្ហានេះ គឺបណ្ដាលមកពីកំណើនដ៏ឆាប់រហ័សនៃបណ្ដាជនសៀមនេះឯង ព្រមទាំងការវិវត្តន៍នៃស្ថានភាពនយោបាយសង្គមជាតិ ក្នុងភូមិភាគ អាស៊ីអាគ្នេយ៍នេះមកបូកបន្ថែមទៀត ។

ប្រជាជនសៀមនឹង ៖ ៧០ ០០០.០០០ ដល់ឆ្នាំ ២០០០!

បើតាមស្ថិតិដែលត្រូវបានគេសម្រេចឡើង តាមបែបបទវិទ្យាសាស្ត្រ កំរិតគ្រោ នៃកំណើនបណ្ដាជនសៀមឡើងដល់ទៅ ៣០%[១] ឯខ្មែរយើងមានត្រឹមតែ ២,៦%

---

(១) យោងតាមសៀវភៅ : « L' Evolution de la Thailande Contemporaine » និងសៀវភៅ «L'Economie de l'Asie du Sud Est » Lê Thanh Khoi, P.U.F. Paris, 1964.



តែប៉ុណ្ណោះ ។

ហេតុដូច្នេះហើយ បើប្រសិនជាគ្មានព្រឹត្តិការណ៍ឯណាមកទាន់ដល់ការវិវត្តន៍បណ្ដាជននេះទេ ប្រទេសសៀមនឹងបានមានមនុស្សដល់ទៅជិត ៧០ លាននាក់ នាដើមសតវត្សទី ២១ ខាងមុខនេះ ( ឯកំណើនបណ្ដាជនខ្មែរយើងនឹងឡើងដល់ ១៨ លាននាក់តែប៉ុណ្ណោះ ) ។ ហេតុដែលបណ្ដាជនសៀមនេះ កើនក្នុង ៣០ឆ្នាំខាងមុខនេះដល់ទៅ ៧០ លាននាក់នេះ មិនមែនជាការងាយស្រួលឲ្យយើងនៅស្ងៀមព្រងើយកន្ដើយសោះឡើយ ។ ដែនដីសណ្ដូចិន នឹងក្លាយទៅជាដែនដីដែលមានបណ្ដាជនច្រើនហួសហេតុ ( Une région surpeuplée ) ។ ព្រោះតែសៀមនិងយួនបូកបញ្ចូលគ្នាកើនដល់ទៅជាង ១៥០ លាននាក់ ., យើងដែលមានត្រឹមតែ ១៨ លាន គឺ ១ ប្រឆាំងនឹង ១០ គឺមានមហន្តរាយគ្រប់គ្រាន់ណាស់ខាងនឹង ( សង្គ្រាម ) យើងបានទេ . បើនរួមគ្នាជាធ្លុងមួយហើយ

ឥទ្ធិពលចំណាប់អារម្មណ៍មកលើប្រទេសយើង ។ ប្រទេសយើង គឺជាដែនដីមួយដែលមាន ស្ថានភាពភូមិសាស្ត្រនយោបាយ ( Une position géo— politique centrale ) នៅកណ្តាលគេ, ហើយដែលគេ ( ប្រសិនបើគេត្រូវរួមគ្នា ) អាចសង្កត់ពីគ្រប់ទិសបានយ៉ាងងាយ ។ បើយើងពិនិត្យមើលតាមព្រឹត្តិការណ៍ក្នុងលោកនេះមកតាំងពីបុរាណ គឺស្ថានភាពភូមិសាស្ត្រប្រទេស ប៉ូឡូញ នៅអឺរ៉ុប ។ ប្រសិនបើយើងមើលទៅប្រទេសប៉ូឡូញនោះ , ជួនកាលត្រូវបាត់បង់ដែនដី , បាត់ឈ្មោះពីផែនទីពិភពលោក , ជួនកាលទៀតប្រទេស អាល្លឺម៉ង់ពីខាងលិច និងប្រទេសរុស្ស៊ីពីខាងកើតស្រវាស្រូបយកគ្នា ( ហែកដែនដីចែកគ្នា ) ដូចកាលពីសម័យសង្គ្រាមលោកលើកទី ២ នេះស្រាប់ៗហើយ ។

ដូច្នេះហើយ, ក្នុងអនាគតនេះ បញ្ហាដែលចោទមកលើកម្ពុជា គឺបញ្ហាចង្អៀតចង្អល់នៃដែនដី ដែលបណ្តាលមកពីបណ្តាជនច្រើនហួសមាននេះឯងជាប្រាកដ ។



## ផលវិបាក បណ្តាលមកអំពីកំណើន បណ្តាជនក្នុងប្រទេសសៀម ។

តើរដ្ឋាភិបាលសៀមមានដោះស្រាយបែបណា ចំពោះបញ្ហាកំណើនចំនួនបណ្តាជននេះ ?

គ្រាន់តែក្នុងសតវត្សរ៍នេះ ដែលបណ្តាជនមានចាប់តាំងកើតដល់ ៦០.០០០ ០០០ នាក់ផងនោះ បានបង្កើតឲ្យមានការព្រួយបារម្ភមួយយ៉ាងធំធេងក្នុងចំណោមអ្នកដឹកនាំសៀម ។ នាឆ្នាំ ១៩៦៧-៦៨ , តាមសេចក្តីសុំពីរដ្ឋាភិបាលសៀម របស់គណៈកម្មការមួយនៃធនាគារពិភពលោក ( la B.I.R.D. ) បានមកធ្វើការសិក្សានិងសេចក្តីរាយការណ៍មួយ អំពីស្ថានភាពសេដ្ឋកិច្ចសៀម ។ យោបល់រួមនៃសេចក្តីរាយការណ៍នេះ បានបង្ហាញឲ្យឃើញនូវកង្វះខាត និង ការតម្រូវការយ៉ាងច្រើនចំពោះអនាគតសេដ្ឋកិច្ចសៀម ។

ផ្ទុយទៅវិញ, ការពង្រីកផលនានាសេដ្ឋកិច្ច គឺបង្កើនផលិតផលកសិកម្មនិងឧស្សាហកម្ម ជាការចាំបាច់ដើម្បីដោះ

ស្រាយបញ្ហាកំណើនបណ្ដាជននេះ , ដើម្បីរក្សាកុំឲ្យកំរិតជីវភាពនៃប្រជាកសិករធ្លាក់ចុះជាលំដាប់ រហូតដល់ការខ្វះខាតគ្រឿងគ្រប់ ទូះចំណីអាហារបរិភោគ ។

សម័យបច្ចុប្បន្ននេះធនធានសេដ្ឋកិច្ចខ្វះៗដែលពីមុនគាបត្រូវគេនាំចេញទៅបរទេសបាន គឺកាន់តែមានចំនួន ថោយជយជាលំដាប់ មានឈើមៃសាក់, សំណ, ដុំហាំង, កៅស៊ូ, ហើយពិសេសទៅទៀត គឺអង្ករនេះតែម្ដង ។

ហេតុដូច្នេះហើយបានជាការពង្រីកសេដ្ឋកិច្ច ឲ្យបានលឿនឆាប់រហ័ស បានក្លាយជាអាទិភាពទីមួយនៃនយោបាយសៀម ។

ក៏ក្នុងគំនិតនេះហើយ ដែលរដ្ឋាភិបាល សៀមសព្វថ្ងៃនេះកំពុងតែស្ថាបនានូវគ្រោងការ ធំៗជាច្រើន មានសំណង់ទំនប់ជលាគ្គិសនី ដែលអាចឲ្យសម្រេចជាមួយផង នូវការបាចទឹកបញ្ចូលស្រែ ( l'irrigation ) និងការពង្រីកនូវផ្ទៃដីដាំដំណាំថ្មីៗទៀត ។ រីឯខាងវិស័យឧស្សាហកម្មវិញ មូលធនបរ



ទេស ( les capitaux étrangers ) ជាច្រើនបានត្រូវគេប្រើប្រាស់ក្នុងប្រទេសដើម្បីសម្រេច ឲ្យមាននូវការចម្រើនលូតលាស់ ។ ក្នុងចំណោមមូលធនប្រទេសដែលគេបានធ្វើវិនិយោគក្នុងប្រទេសនេះ គឺមានមូលធនជប៉ុន ច្រើនជាងគេ, បន្ទាប់មកមូលធនចិនតាយ-វ៉ាន់ ហើយទីបីគឺមូលធនអាមេរិកាំង ។ ក្នុងនយោបាយសេដ្ឋកិច្ចនេះ រដ្ឋាភិបាលបានធ្វើការ សម្រួលឲ្យជាអតិបរមា ដល់ការនាំចូលមក នៃមូលធនបរទេសទាំងនេះ ។

គឺប៉ុន្តែ បញ្ហាដែលសំខាន់ជាងគេ គឺបញ្ហាស្រូវអង្ករនេះឯង ។ វាលទំនាបនៃទន្លេមេណាម ជាមហាជម្រកស្រូវនៃប្រទេសសៀម ។ ក្នុងកាលសព្វថ្ងៃនេះ ផ្ទៃក្រឡាដីដាំដំណាំមានចំនួនតែ ១ភាគ៤ តែប៉ុណ្ណោះ នៃវាលទំនាបទន្លេមេណាម ដែលសម្បូណ៌ទៅដោយជលសារ ។ ដូច្នេះបញ្ហានៃការពង្រីកដីដាំដំណាំមិនមែនទៅតាមក្នុងលក្ខណៈតូចតូច ដូចនៅប្រទេសយៀកណាមខាងណោះទេ ។ ដែនដីសៀមដែលមាននៃផ្ទៃ

ក្រឡាទាំងអស់ជាង : ៤០០ ០០០ គ.ម.២ ហើយដែលមួយភាគយ៉ាងធំជាដីទំនាប ដីនឹងមិនទាន់ក្លាយ ទៅជាដីបង្កើត បង្កើលនៅឡើយទេ ក្នុងរយៈកាល ៣០ ឬ ៤០ ឆ្នាំទៅខាងមុខនេះ ។ ប្រទេសនេះអាចនឹងបង្កើន ផលិតផលកសិកម្មបានថែមទៀត ដើម្បីអាចឆ្លើយតបទៅ នឹងសេចក្តីត្រូវការកាន់តែធំឡើង ៗ នៃប្រជារាស្ត្រ ដោយសារនយោបាយធ្វើឲ្យរីកកែប្រសើរឡើង នូវរបៀបធ្វើកសិកម្ម មានការបាចទឹកបញ្ចូលស្រែ ការប្រើជីគីមី ឬ ប្រើគ្រឿងយន្តកសិកម្ម ។ ដីនៅក្នុងចំណោមនេះឯងហើយ ដែលរដ្ឋាភិបាលសៀមកំពុងតែអនុវត្ត គម្រោងការធំ ៗ ជាច្រើន ខាងទំនប់ទឹក និងប្រឡាយបញ្ចូលស្រែ តាំងពីឆ្នាំ ១៩៥០ មកម្ល៉េះដោយសារជំនួយពិភពលោក ។ គម្រោងការនេះ គេបពង្រីក នូវផ្ទៃក្រឡាដីដាំដំណាំ ព្រមទាំងថាមពល អគ្គិសនីទៀតផង ។

ប្រសិនបើគម្រោងការ ពង្រីកផលិតផលកសិកម្មនិង



ធនធានឧស្សាហកម្មនេះ បាននាំជោគជ័យមែន បញ្ហាថៃក្តីថ្វីសង្គមអាចនឹងត្រូវបានដោះស្រាយ ឲ្យបានធូរស្រាលខ្លះ, គឺប៉ុន្តែកម្លាំងសេដ្ឋកិច្ចសៀម នឹងរីកតែមាន ទំហំធំឡើងជាលំដាប់ អាស្រ័យទៅលើ ភាគធំបេធ នៃផ្សារក្នុងប្រទេសសៀមនេះជាគ្រោះដ (ពី ៦៤ ទៅ៧០ លាននាក់ ដល់ចុងសតវត្សទី ២០') ។ ក្នុងករណីនេះ ការពង្រីកកម្លាំងសេដ្ឋកិច្ចសៀមនេះ គឺអាចក្លាយ ទៅជាគ្រោះថ្នាក់ មួយធំដែរទៅលើអនាគត ប្រទេសកម្ពុជាយើង ដែលមានផ្សារក្នុងប្រទេសទន្ទ្រាយនៅឡើយ ។ ជាការពិតមែនហើយ កម្លាំងសេដ្ឋកិច្ចក្នុងតំបន់និមួយ ៗ នៃពិភពលោក ប្រៀបបាននៅនឹងកម្លាំងទឹកដែលហូរហៀរ ពីតំបន់មួយខ្ពស់ទៅ តំបន់មួយទៀតដែលទាប ជានិច្ចជាដែរ ។

ឯប្រទេសកម្ពុជាយើង ដែលស្ថិតនៅកណ្ដាល ប្រទេសទាំងពីរនេះ ទុកជាយើងធ្វើយ៉ាងណា ៗ ក្តី គឺពុំអាចចៀសផុតអំពីការសង្កត់សង្កិនកាន់តែខ្លាំងឡើងខាងផ្នែកសេដ្ឋកិច្ច និង

បណ្តាផល ( les pressions d'ordre économique et démographique grandissantes ) នៃប្រទេសទាំងសងខាងបានខ្ពស់ឡើង ដោយការស្រើយទៅលើហេតុថា គេពុំអាចធ្វើព្រំប្រទល់ផែនឯណាឲ្យបិទជិតស្លូឈឹងបានឡើយ រវាងប្រទេសជិតខាងគ្នា ។

តើប្រទេសកម្ពុជាយើង ដែលមានលក្ខណៈជាដែកទ្រនាប់មួយតូច អាចទ្រទ្រង់ទប់ទល់នឹងញញួរធំ ៗ ដល់ទៅពីរ ដែលញាក់មកលើខ្លួនព្រមៗគ្នា, បានឬទេ ក្នុងអនាគតខាងមុខនេះ ? វាជាការពិតណាស់ទៅហើយ, ដើម្បីនឹងអាចទ្រាំទ្របាន លុះត្រាតែដែកទ្រនាប់នេះ ត្រូវគេបន្ថែមស្រទាប់ដែកឲ្យបានក្រាស់មាំផងមុននឹងបាន ។

ម្យ៉ាងទៀត ចំពោះករណីសៀមនេះទៀតសោត បើសិនជាប្រទេសនេះអាចសម្រេចដោយជោគជ័យខាងការពង្រីកកម្លាំងសេដ្ឋកិច្ចបាន នោះជាការប្រសើរហើយ ។ តែបើផ្ទុយទៅវិញ, តើនឹងមានការដោះស្រាយឯណាទៀត ? ច្បាស់



ជាអ្នកដឹកនាំសៀម នេះនឹងពោលតែកញ្ញយៗ មកលើដែនដីដ៏មានជីជាតិនៃ ខេត្តបាត់ដំបង និងរាលទំនាបនៃបឹងទន្លេសាប ដែលសម្បូរ ទៅដោយត្រីសាច់ និងស្រូវអង្ករមិនខានឡើយ ។ ចុះបើគេឃុបឃិត ជាមួយជនជាតិយួនទៀតដើម្បីបែងចែកផែនដីយើង, ដូចនៅសតវត្សរ៍ទី ១៩ ឆ្នាំ ១៨៤០ តើយើងនឹងឈមមុខទប់ទល់នឹងគម្រោងការអកុសលនេះ តាមវិធីណា ?

x

x x

# សេចក្ដីបញ្ចប់

ទាំងអស់នេះ, គឺគ្រាន់តែជាការសន្និដ្ឋាន ការប្រឌិត ដែលជាលទ្ធផល នៃប្រាជ្ញានិងការយល់តែប៉ុណ្ណោះ មិនទាន់មានជាការពិត នៃប្រវត្តិសាស្ត្រនោះទេឡើយ ។ តែ, ពេលណាឡើយ ដែលអាចហៅនេះបានជា គុណអនាគត, ការប្រឌិតនេះមិនអាចក្លាយជាជាក់លាក់ ទៅជាការពិតក្នុងប្រវត្តិសាស្ត្របាន ។ ប្រវត្តិសាស្ត្រអាចឲ្យមេរៀនផង មិនឲ្យមេរៀនផងចំពោះយើងរាល់គ្នា ។ អនាគតកាលគឺជារូបនិមិត្តមួយដែលគេគប្បីឲ្យយើងចូលទៅក្នុង ដោយឥតប្រាកដបានឡើយ តែបើយើងដឹងមុនជារួមនេះ មានកិច្ចការ យ៉ាងម៉េច ៗ ខ្លះហើយ, យើងក៏អាចប្រុងប្រៀបខ្លួនយើងបានច្រើនដែរ ដើម្បីឈមមុខនឹងយថាហេតុ គ្រប់បែបយ៉ាង ។

ហេតុដូចបានអធិប្បាយដោយគ្រួស ៗ ពីខាងលើនេះ យើងអាចសន្មត ដោយមានការកាន់ប្រយ័ត្ន ជាឧបាយមេ ជាចំពោះអនាគតកាល នៃប្រទេសកម្ពុជាយើង , ឯណាយពេលមេឃ ឯណោះ សុទ្ធតែប្រកបទៅដោយអ៊ុំពុកកន្ទ្រា ។ ច្រើនជាងនេក



កម្លាំងនៃការសន្តិសុខ ខាងផ្លូវសេដ្ឋកិច្ចជាមួយគ្នានឹងផ្លូវបណ្ដាជន មិនផ្លូវនយោបាយថែមទៀតផង ជាការកំរបកំហែង មួយយ៉ាងធំឥតប្រៀបផ្ទឹមបានដែលប្រទេសយើងត្រូវតែទទួល នេះព្រោះពីសំណាក់នៃអនាគតប្រទេសជិតខាងយើង ។

ក្នុងលក្ខខណៈបែបនេះ, មាគ៌ាដែល យើងត្រូវធ្វើ យើងត្រូវមានការក្ដុកិច្ចជាបឋម រៀបចំសេដ្ឋកិច្ចជាតិយើងផែនលៀនទាន់សម័យនិយម, ធ្វើសេដ្ឋកិច្ចនេះឲ្យរីកចំរើនអភិវឌ្ឍ ដើម្បីអាចឲ្យមានកម្លាំងគ្រប់គ្រាន់ អាចឈមមុខទប់ទល់បាន នឹងកម្លាំង សន្តិសន្តិខពីក្នុក ជិតខាងយើង ដោយធ្វើឲ្យការគំរាមកំហែងដល់ការរស់នៅជីវិតយើង មាចំណាំ យ៉ាងតូចបំផុត ។

បើសេដ្ឋកិច្ចមាន កម្លាំងគ្រប់គ្រាន់ហើយ, នយោបាយក៏ដើរសេដ្ឋកិច្ច ពីក្រោយខ្នងដែរសមនឹង ពាក្យដែលថា គឺសេដ្ឋកិច្ចទៅនាំនយោបាយ ។ គំនិតទាំងអស់នេះគឺគ្រាន់តែជាលទ្ធផល នៃការរិះគិតពិចារណាស៊ីជម្រៅ នៃមនុស្សម្នាក់តែប៉ុណ្ណោះ ដូចនេះពុំទាន់

លក្ខណៈជាសាកលទៀយ ។ ហេតុដូច្នេះហើយ ការផ្គាប់ផ្គងកាន់ទ្រទ្បុំ មិនច្បាស់លាស់តែងមានជាការធម្មតា ។

បំណងរបស់យើងគឺ ការសាកល្បងបំភ្លឺអនាគតកាល ដឹងសម្បូ ជ្ជុះតែប៉ុណ្ណោះ ។

គ្រប់ជនបញ្ញាពន្លឺក សេដ្ឋកិច្ចឲ្យបានជឿនលឿននេះ ស្រេចតែ សមត្ថកិច្ចនៃអ្នកមកក្រោយ ខាងមុខនេះចុះ ។

..សូមប្រទេសកម្ពុជា ជាមាតុភូមិជាទីស្នេហា គង់វង្សជានិច្ច... ក្នុងភាពរុងរឿង ។

កំពង់ចាម ថ្ងៃទី ២០ មករា ១៩៨០

នួន ឃឿន

